ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

Ministry of Environment

លេខ ០៧៨ សជណ បស្ត.អកធ

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០

**សូមជម្រាបជូន**

**ឯកឧត្តម ប្រធានយន្តការប្រតិកម្មរហ័ស ទីស្តីការគណៈរដ្ឋមន្ត្រី**

**កម្មវត្ថុ** : ករណីពាក់ព័ន្ធ និងការចុះផ្សាយព័ត៌មានរបស់កាសែតកម្ពុជាថ្មី លេខ ២១៦២ ឆ្នាំទី៩ ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១០ និងការផ្សាយលេខ ២១៦៧ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១០ លើអត្ថបទដែលមានខ្លឹមសារប៉ះពាល់ដល់ការគ្រប់គ្រងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រខេត្តកំពង់ស្ពឺ ។

**យោង** : -អត្ថបទសារព័ត៌មានរបស់កាសែតកម្ពុជាថ្មី លេខ ២១៦២ ឆ្នាំទី ០៩ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០

-អត្ថបទសារព័ត៌មានរបស់កាសែតកម្ពុជាថ្មីលេខ ២១៦៧ ឆ្នាំទី ០៩ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១០

-លិខិតលេខ ០១៤/១០ រប.ដឱរ.អកធ.បស្ត ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០ របស់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រ ខេត្តកំពង់ស្ពឺ

-លិខិតលេខ ០១៥/១០ រប.ដឱរ.អកធ.បស្ត ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០ របស់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រ ខេត្តកំពង់ស្ពឺ

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា: ថ្មីៗនេះអត្ថបទកាសែតកម្ពុជាថ្មី លេខ ២១៦២ ឆ្នាំទី ០៩ ចុះផ្សាយថ្ងៃព្រហស្បតិ៍ ទី ២៨ ខែ មករា ឆ្នាំ ២០១០ ក្រោមចំណងជើង”សត្វព្រៃនិងព្រៃឈើនៅស្រុកឱរ៉ាល់អាចឈានទៅរកការបាត់បង់ដោយមន្ត្រីជំនាញ” និងការផ្សាយលេខ ២១៦៧ ចុះថ្ងៃពុធ ទី០៣ ខែកុម្ភៈ ឆ្នាំ ២០១០ ក្រោមចំណងជើងថា”មន្ត្រីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ឃុបឃិតជាមយយខក្រុិដ្ឋជនបើកភ្លើងខៀវឱ្យអ្នកដាក់ម៉ាស៊ីនរែអារឈើ” ដែលការចុះផ្សាយទាំងពីរលើកនេះគឺជាព័ត៌មានមិនពិតនោះទេ ។ ព្រោះថាបទល្មើសព្រៃឈើដែលបានជញ្ជូនចេញពីចំនុចខ្សាល់ ស្ថិតក្នុងភូមិរស្មីសាមគ្គី ឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺនេះជាតំបន់ដែលគ្រប់គ្រងរដ្ឋបាល់ព្រៃឈើ តែមិនមានព្រំប្រទល់ជាប់នឹងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ទេ ម្យ៉ាងទៀតឈើដែលបានដឹកជញ្ជូនកន្លងមកនេះ គឺដឹកចេញពីតំបន់អភិរក្សជួរភ្នំក្រវាញភាគកណ្តាល ដែលមិនមានជាយុត្តាធិការរបស់ក្រសួងបរិស្ថានឡើយ។ រីឯទាក់ទិនចំពោះការចោទប្រកាន់របស់ដែលថា ព្រៃឈើជាដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ រងការបំផ្លាញអស់៥០ភាគរយនោះ គឺមិនពិតនោះទេព្រោះព្រៃឈើក្នុង

តំបន់នេះពុំមានការកាប់បំផ្លាញជាលក្ខណជាអាជីវកម្មទេ គឺជាសកម្មភាពរបស់ប្រជាសហគមន៍មូលដ្ឋានធ្វើការដកហូតតែអនុផលព្រៃឈើសម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃតែប៉ុណ្ណោះដូចជា ការកាប់អុសការ៉េសសម្រាប់ប្រើប្រាស់នៅមូលដ្ឋានជាដើម ឯបទល្មើសកាប់បំផ្លាញឈើធំៗដើម្បីធ្វើអាជីវកម្មនោះ ពុំដែលកើតមានក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ក្នុងភូមិសាស្ត្រ ខេត្តកំពង់ស្ពឺឡើយ តែវាក៏ជាតំបន់ឆ្លងកាត់តែប៉ុណ្ណោះ ហើយមន្ត្រីប្រចាំការនៅទីនោះក៏បានធ្វើការបង្រ្កាប និងរិបអូសវត្ថុតាងទាំងនោះជារើយៗផងដែរ ។ ម្យ៉ាងទៀតការគ្រប់គ្រងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់នេះមានការចូលរួមគ្រប់គ្រងពីប្រជាសហគមន៍មូលដ្ឋានសហការជាមយយកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ចូលរួមទាំងមន្ទីរបរិស្ថានផងដែរ ។

កន្លងមកតាមរយៈការអនុវត្តច្បាប់ស្តីពី តំបន់ការពារធម្មជាតិ ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ បានធ្វើការបង្រ្កាបបទល្មើសលើធនធានធម្មជាតិ និងបានចាត់បញ្ជូនជនប្រព្រឹត្តបទល្មើសមួយចំនួនទៅសាលាដំបូងខេត្តកំពង់ស្ពឺ ដើម្បីផ្តន្ទាទោសតាមច្បាប់ ដែលនេះជាហេតុធ្វើឱ្យជនទាំងអស់នេះមានការខឹងសម្បា និងរកគ្រប់វិធីដើម្បីបង្ខូចឈ្មោះមន្ត្រីគ្រប់គ្រងនៅដែនដីជម្រកសត្វព្រៃភ្នំឱរ៉ាល់នេះ ។

ដោយឡែកចំពោះការចោទប្រកាន់របស់កាសែតកម្ពុជាថ្មីដដែលនោះអំពីការឃុបឃិតគ្នារវាងមន្ត្រីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ជាមួយឧក្រិដ្ឋជនបើកភ្លើងខៀវឱ្យអ្នកដាក់ម៉ាស៊ីនអារឈើនោះ គឺកើតឡើងក្រោយពីលោកនាយកដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់បានទទួលទូរស័ព្ទពីមនុស្សមួយចំនួន ដែលអះអាងថាជាអ្នកកាសែតប្រចាំសារព័ត៌មានឈ្មោះនេះឈ្មោះនោះបានទូរស័ព្ទមក ជំរិតទារប្រាក់ពីរូបគាត់ពី ១០០ ទៅ ១៥០ ដុល្លា ក្នុងម្នាក់ដើម្បីយកទៅដោះស្រាយមធ្យោបាយធ្វើដំណើរ និងដាក់កាតទូរស័ព្ទជាដើម តែលោកនាយកបានប្រាប់វិញថាប្រាក់ខែរបស់គាត់មិនទាំងគ្រប់ចំនួនទារនេះផងដូចនេះមិនមានប្រាក់ឯណាសម្រាប់ឱ្យអស់លោកបានទេ។ ទាំងនេះគឺជាដើមចមធ្វើឱ្យអ្នកទាំងនោះរកមធ្យោបាយចុះកាសែតបំភ្លើសការពិតជាក់ស្តែងនៅក្នុងតំបន់ ដើម្បីបង្ខូចឈ្មោះ និងធ្វើឱ្យមតិសាធារណៈជមមានការភាន់ច្រឡំ ។

ហេតុដូចនេះ ខ្លឹមសារព័ត៌មានដែលចុះផ្សាយថ្ងៃព្រហស្បតិ៍ ទី ២៨ ខែ មករា ឆ្នាំ ២០១០ និង ថ្ងៃ ពុធ ទី០៣ ខែកុម្ភៈ ឆ្នាំ ២០១០ គឺជាព័ត៌មានបំភ្លើសការពិត ហើយចុះនេះទៀតសោតវាកើតចេញពីជនល្មើសដែលមានការខឹងសម្បាជាមួយការអនុវត្តច្បាប់របស់មន្ត្រីប្រចាំការនៅដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងការដែលអ្នកយកព័ត៌មានទាំងនោះជំរិតទារប្រាក់ពីលោកនាយកដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រខេត្តកំពង់ស្ពឺ មិនបានសម្រេច ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាបតាមការគួរ ។

សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក ម៉ារ៉េត**

បណ្ឌិត.ជីវវិទ្យា

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងព័ត៌មាន

-សាលាខេត្តកំពង់ស្ពឺ

-អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

-មន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺ

-ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ

-ឯកសារ.កាលប្បវត្តិ